# ការជ្រើសរើសដែលជះឥទ្ធិពលលើភាពអស់កល្បជានិច្ច ផ្នែកទី ២



ទីពីរ ៖ ស្គាល់សេចក្ដីពិតអំពីអ្វីដែលព្រះវរបិតាសួគ៌ និងព្រះរាជបុត្រារបស់ទ្រង់គឺព្រះយេស៊ូវគ្រីស្ទបានប្រទានដល់ក្មួយៗ ។

សរុបមក ទ្រង់ទាំងទ្វេបានប្រទានឲ្យក្មួយៗនូវអ្វីៗគ្រប់យ៉ាង !

ផែនការរបស់ព្រះវរបិតាសួគ៌សម្រាប់បុត្រាបុត្រីរបស់ទ្រង់អនុញ្ញាតឲ្យយើងរស់នៅកន្លែង និងរបៀបដែលទ្រង់រស់នៅ ហើយទីបំផុតនឹងក្លាយកាន់តែដូចទ្រង់ ។ ផែនការរបស់ទ្រង់ពិតជាធ្វើឲ្យពរជ័យដ៏ធំបំផុតនៃភាពអស់កល្បជានិច្ច កើតមានដល់យើង រួមទាំងសក្ដានុពលដើម្បីយើងបាន « គ្រងមរតកជាមួយនឹងព្រះគ្រីស្ទ » ផងដែរ [ រ៉ូម ៨:១៧ ] ។

ព្រះយេស៊ូវស្រឡាញ់មនុស្សទាំងអស់ និងទតមើលលើមនុស្សទាំងអស់ ។ នៅក្នុងភាពអស់កល្បជានិច្ច គ្មាននរណាម្នាក់នឹងស្គាល់ក្មួយៗ ឬខ្វល់ខ្វាយនឹងក្មួយៗខ្លាំងជាងទ្រង់ឡើយ ។ គ្មាននរណាម្នាក់នឹងនៅជិតក្មួយៗជាងទ្រង់នោះទេ ។ ក្មួយៗអាចថ្វាយដួងចិត្តចំពោះទ្រង់ និងទុកចិត្តទ្រង់ឲ្យបញ្ជូនព្រះវិញ្ញាណបរិសុទ្ធ និងពួកទេវតាមកថែរក្សាក្មួយៗ ។ ទ្រង់បានបង្ហាញសេចក្ដីស្រឡាញ់ដ៏ធំធេងបំផុត នៅពេលទ្រង់បានបញ្ជូនបុត្រាបង្កើតតែមួយគត់របស់ទ្រង់ឲ្យមកសុគតសម្រាប់ក្មួយៗ—ធ្វើជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះរបស់ក្មួយៗ !

តាមរយៈដង្វាយធួនរបស់ទ្រង់ ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទបានឈ្នះលើលោកិយ [ សូមមើល យ៉ូហាន ១៦:៣៣; គោលលទ្ធិ និងសេចក្ដីសញ្ញា ៥០:៤១ ] ។ ហេតុដូច្នោះហើយ ទ្រង់មាន « ឥទ្ធិឫទ្ធិដើម្បី . . . ជម្រះ [ ក្មួយៗ ] ឲ្យជ្រះពីអស់ទាំងអំពើដ៏ឥតសុចរិត » [ អាលម៉ា ៧:១៤ ] ។ ទ្រង់នឹងរំដោះក្មួយៗចេញពីស្ថានភាពដ៏ឈឺចាប់បំផុតរបស់ក្មួយៗ តាមរបៀប និងពេលវេលារបស់ទ្រង់ផ្ទាល់ ។ កាលដែលក្មួយៗមករកទ្រង់ដោយសេចក្ដីជំនឿ នោះទ្រង់នឹងដឹកនាំ ថែរក្សា និងការពារក្មួយៗ ។ ទ្រង់នឹងព្យាបាលចិត្តសង្រេងរបស់ក្មួយៗ ហើយលួងលោមក្មួយៗនៅគ្រារងទុក្ខ [ សូមមើល លូកា ៤:១៨; អាលម៉ា ៧:១០–១២ ] ។ ទ្រង់នឹងប្រទានឲ្យក្មួយៗទទួលបានព្រះចេស្ដារបស់ទ្រង់ ។ ហើយទ្រង់នឹងធ្វើឲ្យអ្វីដែលពុំអាចធ្វើទៅបានក្នុងជីវិតក្មួយ ប្រែជាអាចធ្វើទៅបាន ។ . . .

ព្រះមានសេចក្ដីស្រឡាញ់ដ៏ពិសេសចំពោះបុគ្គលម្នាក់ៗ ដែលចុះសេចក្ដីសញ្ញានឹងទ្រង់នៅក្នុងទឹកនៃពិធីបុណ្យជ្រមុជទឹក ។ ហើយសេចក្ដីស្រឡាញ់ដ៏ទេវភាពនោះមានកាន់តែខ្លាំង នៅពេលសេចក្ដីសញ្ញាបន្ថែមទៀតបានធ្វើឡើង និងគោរពតាមយ៉ាងស្មោះត្រង់ ។ បន្ទាប់មកនៅចុងបញ្ចប់នៃជីវិតរមែងស្លាប់នេះ ការជួបជុំរបស់បុត្រនៃសេចក្ដីសញ្ញាម្នាក់ៗជាមួយនឹងព្រះវរបិតាសួគ៌គឺជារឿងដ៏មានតម្លៃ [ សូមមើល ទំនុកដំកើង ១១៦:១៥ ] ។

ទ្រង់ក៏ខ្វល់ព្រះទ័យ *យ៉ាងខ្លាំង* ដើម្បីឲ្យបុត្រាបុត្រីរបស់ទ្រង់គ្រប់រូបមានឱកាសស្ដាប់ឮដំណឹងដ៏រីករាយនៃដំណឹងល្អដែលបានស្ដារឡើងវិញនេះ ។ ព្រះវរបិតាសួគ៌បានចាត់បុត្រាបុត្រីរបស់ទ្រង់ឲ្យមកកាន់ផែនដីជាងប្រាំមួយសហសវត្សរ៍ហើយ ។ ភាគច្រើនមនុស្សទាំងនេះពុំទាន់ទទួលបានពិធីបរិសុទ្ធដែលនឹងធ្វើឲ្យពួកគេមានគុណសម្បត្តិគ្រប់គ្រាន់ ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចនៅឡើយទេ ។ នោះជាហេតុផលដែលព្រះវិហារបរិសុទ្ធមានសារៈសំខាន់យ៉ាងខ្លាំង ។ នោះគឺជាហេតុដែលការប្រមូលផ្ដុំនៃអ៊ីស្រាអែលនៅទាំងសងខាងវាំងនន គឺជា *បុព្វហេតុ* ដ៏សំខាន់បំផុតនៅលើផែនដីនាសព្វថ្ងៃនេះ ។ មិត្តរួមការងារជាទីស្រឡាញ់នៅក្នុងកិច្ចការដ៏បរិសុទ្ធនេះ ក្មួយៗមានតួនាទីដ៏សំខាន់នៅក្នុងការប្រមូលផ្ដុំនេះ ហើយខ្ញុំសូមអរគុណក្មួយៗសម្រាប់តួនាទីនោះ ។ ( រ័សុល អិម ណិលសុន « ការជ្រើសរើសដែលជះឥទ្ធិពលលើភាពអស់កល្បជានិច្ច » [ ការប្រជុំធម្មនិដ្ឋានទូទាំងពិភពលោកសម្រាប់ យុវមជ្ឈិមវ័យ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២ ] នៅលើគេហទំព័រ broadcasts.ChurchofJesusChrist.org )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_544_handout-2